**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

# របាយការណ៍លទ្ធផល
# ស្តីពី
# ការរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៨
# វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីពី ទិវាជាតិអំណាន។ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់សហការជាមួយក្រសួងពាក់ព័ន្ធ និងអង្គការដៃគូអភិវឌ្ឍជាតិ អន្តរជាតិ រៀបចំប្រារព្ធពិធីទិវាជាតិអំណាន បានពីរលើករួចមកហើយ លើកទី១ក្រោមប្រធានបទ " **បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន** " នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយមានអ្នកចូលរួម ១៨៨៣ នាក់ ដែលសកម្មភាពសំខាន់មានការតាំងពិព័រណ៌សៀវភៅ សកម្មភាពនិទានរឿង អានរឿង និងសូត្រកំណាព្យ និងលើកទី២ ក្រោមប្រធានបទ " **អានដើម្បីភាពសុខដុមនៃជីវិត** " នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ ដោយមានអ្នកចូលរួម ២១០០ នាក់ ដែលក្នុងនោះមាន ការប្រកួតប្រជែងអាន និងសូត្រកំណាព្យ ជាលើកដំបូងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** "។ ដោយឡែកនៅឆ្នាំ២០១៨នេះ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ បានរៀបចំទិវាជាតិអំណានលើកទី៣ ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " ដែលបានប្រព្រឹត្តឡើងពីថ្ងៃទី០៩ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ។ ការប្រារព្ធទិវាជាតិអំណានលើកទី៣នេះ មានទំហំធំជាងលើកទី១ និងទី២ ដោយមានកម្មវិធីប្រកួតប្រជែងអានសម្រាប់សិស្សថ្នាក់ទី៦ សូត្រកំណាព្យសម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ និងតែងនិពន្ធសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ដើម្បីទទួលជ័យលាភី " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បេក្ខជនជ័យលាភី លេខ១ លេខ២ និងលេខ៣ ទាំង៣វិញ្ញាសារ និងបានរៀបចំស្តង់ពិព័រណ៌សៀវភៅជាស្នាដៃរបស់វីរៈជនជាតិ ស្ថាប័នជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល មានដូចជា ស្តង់តាំងពិព័រណ៌សៀវភៅរបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្តង់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ស្តង់ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ក្រុមហ៊ុន និងអង្គការដៃគូរជាច្រើនទៀត។

## I. គោលបំណង

ក្រសួងអប់រំ យុវជន និងកីឡា បានសហការរៀបចំប្រារព្ធទិវាជាតិអំណានថ្ងៃ១១ មីនា ឆ្នាំ២០១៨ លើកទី៣ ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " ក្នុងគោលបំណង៖

- លើកកម្ពស់សមត្ថភាព អាន សូត្រកំណាព្យ និងការតែងនិពន្ធ
- បណ្តុះទំលាប់អាន វប្បធម៌អាន និងការតាក់តែងនិពន្ធសំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌អរិយធម៌ខ្មែរ។

## II. **យុទ្ធវិធី**

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានឆ្នាំ២០១៨នេះ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីសម្រេចលេខ ៣១ អយក.សសទ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០១៧ ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន។ ក្នុងការបំពេញបេសកកម្មនេះ គណៈកម្មការបានសហការជាមួយក្រសួងស្ថាប័ន និងអង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍពាក់ព័ន្ធមានដូចជា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ដើម្បីបង្កើតគណៈកម្មការវាយតម្លៃដាក់ពិន្ទុដល់បេក្ខជនក្នុងការប្រកួតប្រជែងអាន សូត្រកំណាព្យ និងតែងនិពន្ធ។ ក្រសួង ក៏បានសហការយ៉ាងជិតស្និតជាមួយស្ថាប័នជាតិ ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ មានដូចជា ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ អង្គការយូណេស្កូ អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា អង្គការRoom to Read អង្គការ Sipar អង្គការSVA គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ អង្គការSave the Children និងក្រុមហ៊ុនស្មាតហ្វូនកម្ពុជា ក្នុងការសហការរៀបចំ និងឧបត្ថម្ភ។

ដំណើរការនៃការរៀបចំប្រារព្ធពិធីទិវាជាតិអំណាន បានប្រព្រឹត្តទៅជា២សកម្មភាពគឺ សកម្មភាពត្រៀមការប្រារព្ធពិធី និងសកម្មភាពប្រារព្ធពិធីទិវាជាតិអំណាន ១១ មីនា ២០១៨ ។

១- សកម្មភាពមុនការប្រារព្ធពិធី ៖ ជាការរៀបចំផែនការសកម្មភាពសម្រាប់រៀបចំទិវាជាតិអំណាន និងការប្រជុំ របស់ក្រុមការងាររៀបចំទិវាជាតិអំណានជាមួយថ្នាក់ដឹកនាំក្រសួង និងអ្នកពាក់ព័ន្ធ ។

២- សកម្មភាពប្រារព្ធពិធីទិវាជាតិអំណាន ១១ មីនា ២០១៨។ សកម្មភាពនេះបានប្រព្រឹត្តទៅរយៈពេល ០៣ថ្ងៃ ចាប់ពីថ្ងៃទី០៩ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្នុងនោះមាន ៖

- កម្មវិធីប្រកួតប្រជែងការអាន សូត្រកំណាព្យ និងតែងនិពន្ធ សម្រាប់ជ័យលាភីលេខ១ លេខ២ និងលេខ៣ ដើម្បីទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ។
- កម្មវិធីស្តង់ពិព័រណ៌ ដែលបង្ហាញពីឯកសារជាសមិទ្ធិផលរបស់វិស័យអប់រំ និងសមិទ្ធិផលជាស្នាដៃរបស់វីរៈជនជាតិ អង្គការជាតិ អង្គការអន្តរជាតិ និងក្រុមហ៊ុនផ្សេងៗ។
- កម្មវិធីប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៨ ជាកម្មវិធីដែលបានផ្តល់ និងពិភាក្សាពីខ្លឹមសារទាក់ទងនឹងទិវាជាតិអំណាន ជាពិសេស ប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " ។ ក្នុងកម្មវិធីនេះមានសកម្មភាពសំខាន់ៗដូចជា ៖

ក-ការបង្ហាញរបាយការណ៍វឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណាន

ខ-ការសូត្រកំណាព្យ និងការអានអត្ថបទរបស់បេក្ខជនជ័យលាភី និងការប្រគល់ " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ជូនបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ទាំង៣ វិញ្ញាសារ។

គ-ការប្រគល់រង្វាន់ដល់ជ័យលាភីកិត្តិយសក្នុងការបកស្រាយ " *តម្លៃសកលនៃស្នាដៃអក្សរសិល្ប៍រឿងទុំទាវ* "

ឃ-ពិធីផ្តល់សៀវភៅអប់រំផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ក្រោមចំណងជើងថា " *តោះនិយាយពីលុយ* "

ង-ប្រសាសន៍សំណេះសំណាលរបស់លោកជំទាវ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ច-បាឋកថារបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ** ស្តីពី " *ការវិវត្តនៃអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ* "

ឆ-កិច្ចពិភាក្សាលើប្រធានបទ ស្តីពី " *តម្លៃសកលនៃស្នាដៃអក្សរសិល្ប៍ រឿងទុំទាវ* "

ជ-កិច្ចពិភាក្សាលើប្រធានបទ ស្តីពី " *ការតាក់តែងនិពន្ធនៅប្រទេសកម្ពុជា* " ។

## III.សកម្មភាពត្រៀមការប្រារព្ធពិធីទិវាជាតិអំណាន ១១ មីនា ឆ្នាំ២០១៨

### ក-ការរៀបគណៈកម្មការសម្រាប់រៀបចំទិវាជាតិអំណាន

ជាការត្រៀមរៀបចំសម្រាប់សកម្មភាពទិវាជាតិអំណាន១១ មីនា ឆ្នាំ២០១៨ លើកទី៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ សកម្មភាពត្រៀមរៀបចំ មានលំនាំសកម្មភាពជាបន្តបន្ទាប់ដូចខាងក្រោម ៖

- ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីសម្រេចលេខ ៣១ អយក.សសរ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី ការបង្កើតគណៈកម្មការរៀបចំគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន ១១ មីនា ឆ្នាំ២០១៨។

- ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំលេខ ៤៧ អយក.សណន ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៨ ដើម្បីជូនដំណឹងដល់អង្គភាពថ្នាក់ជាតិ និងក្រោមជាតិ ផ្សព្វផ្សាយណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យបានទូលំទូលាយក្នុងការចូលរួមរៀបចំប្រារព្ធទិវាជាតិអំណាន ជាពិសេសអង្គភាពមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត បំផុសរៀបចំគណៈកម្មការប្រកួតប្រជែងជ័យលាភីលេខ១ លេខ២ លេខ៣ លើវិញ្ញាសារអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ។

- ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីជូនដំណឹងលេខ ០៦ អយក.សជណ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៨ ស្តីពី ការប្រឡងប្រជែងជ្រើសរើសជ័យលាភីលេខ១ លេខ២ លេខ៣ ដែលមានសមត្ថភាពក្នុងការបកស្រាយ ប្រធានបទ " ***តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍រឿងទុំទាវ*** " ។

- ក្រសួងបានរៀបចំលិខិតឧទ្ទេសនាម លេខ ៨០៨ អយក.ឧទន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ការចាត់តាំងគណៈកម្មការរៀបចំការប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ដើម្បីអបអរសាទរទិវាជាតិអំណាន ១១ មីនា ២០១៨ ក្រោមប្រធានបទ " អំណានជាកំណប់វិជ្ជាមហាសាល " ដែលមានគណៈកម្មការដាក់ពិន្ទុការប្រកួតប្រជែងអាន ស្មូតកំណាព្យ តែងនិពន្ធ និងគណៈកម្មការសម្របសម្រួលដំណើរការរៀបចំប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ។

### ខ-សកម្មភាពគណៈកម្មការសម្រាប់រៀបចំទិវាជាតិអំណាន

សកម្មភាពរបស់គណៈកម្មការរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៨ មាន ៖

1. កិច្ចប្រជុំថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី ការរៀបចំផែនការប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ទន់ សារ៉ឺម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ លទ្ធផលនៃកិច្ចប្រជុំមាន ៖

ក-ប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** "

ការបកស្រាយខ្លឹមសារប្រធានបទមាន ការអានជាទ្រព្យកំណប់ប្រើមិនចេះរីងស្ងួត អានទទួលបានផលប្រយោជន៍ពីការអាន អានច្រើនមានចំណេះវិជ្ជាទ្រព្យសម្បត្តិនិងកិត្តយសមហាសាល អានច្រើនស្គាល់ខុសត្រូវ ចេះវិភាគ មានគំនិតវិជ្ជមានសម្រាប់ខ្លួនឯង ចំណេះជាទ្រព្យជាប់នឹងប្រាណចោរលួចមិនបាន ចាយច្រើនចម្រើនឡើង អំណានជាគន្លឹះធ្វើឱ្យមនុស្សឆ្ពោះទៅរកគុណធម៌បានល្អ។

ខ-ពាក្យស្លោក មាន ៖

លើកកម្ពស់ការអាននៅកម្ពុជា អំណានជាប្រភពនៃវិជ្ជា អំណានជាគន្លឹះនៃចំណេះដឹង អំណានជាឧត្តមភាពនៃជីវិត អំណានជាប្រទីបបំភ្លឺផ្លូវ អានច្រើនបង្កើនឱកាស អានច្រើនបង្កើនភាពវៃឆ្លាត អានច្រើនកើនចំណេះ អំណានជាវឌ្ឍនភាពនៃវិជ្ជា អានហើយអានទៀតអានគ្រប់ទីកន្លែង អំណានដើម្បីអភិវឌ្ឍខ្លួនឯង គ្រួសារនិងសង្គម អំណានកាត់បន្ថយភាពក្រីក្រ អំណានលើកតម្កើងវប្បធម៌ជាតិ អំណានកាត់បន្ថយហឹង្សា អំណានលើកតម្កើងវប្បធម៌ជាតិ អំណានបង្កើនសេដ្ឋកិច្ចគ្រួសារ មានអំណានមានការអភិវឌ្ឍ មានអំណាន មានចំណេះដឹង ចំណេះធ្វើ វប្បធម៌អានជាគ្រឿងអលង្ការរបស់មនុស្សទូទៅ អំណានក្សាន្តជីវិត

អំណានជាមាតានៃចំណេះដឹង  អំណានជាមូលដ្ឋានគ្រឹះនៃចំណេះវិជ្ជា ។

**គ**. ត្រៀមរៀបចំគណ.កម្មការបច្ចេកទេសរៀបចំការការប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ

**ឃ**.កម្មវិធីប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៨

**ង**-ការដាក់ប្រធានបទ និងពាក្យស្លោក តាម Facebook ដើម្បីបំផុសឱ្យមហាជនចូលរួមផ្តល់យោបល់

**ច**-ការរៀបចំសមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រកួតប្រជែងអាន ស្មូតកំណាព្យ តែងនិពន្ធ។

2. កិច្ចប្រជុំថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ សកម្មភាព និងលទ្ធផលកិច្ចប្រជុំនាឱកាសនោះមាន ៖

- ការរៀបចំផែនការសកម្មភាព និងផែនការថវិកា
- ការរៀបចំលិខិតស្នើសុំទីកន្លែងប្រារព្ធពិធីនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន
- ការរៀបចំសេចក្តីណែនាំស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា
- កម្មវិធីសម្រាប់ប្រារព្ធទិវាជាតិអំណាន និងសមាសភាពចូលរួម
- ការរៀបចំប្រធានបទ " អំណានជាកំណប់វិជ្ជាមហាសាល " និងពាក្យស្លោកសម្រាប់ទិវាជាតិអំណាន ១១ មីនា ២០១៨ មាន **១**. អំណានដើម្បីបណ្តុះទម្លាប់រៀនពេញមួយជីវិត **២**. អំណានលើកកម្ពស់អត្តសញ្ញាណជាតិ **៣**. អំណានថ្ងៃនេះ សម្រាប់ថ្ងៃស្អែក **៤**. អំណានជាប្រភពនៃទ្រព្យមិនចេះរីងស្ងួត **៥**. អំណានជាវឌ្ឍនភាពនៃវិជ្ជា **៦**. អំណានជាគន្លឹះនៃចំណេះដឹង **៧**. អានច្រើនកើនចំណេះ **៨**. អំណានលើកតម្កើងវប្បធម៌ជាតិ **៩**. អំណានជាមូលដ្ឋានគ្រឹះនៃចំណេះវិជ្ជា **១០**. វប្បធម៌អានជាគ្រឿងអលង្ការរបស់មនុស្សទូទៅ។

3. កិច្ចប្រជុំថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អនុគណៈកម្មការបច្ចេកទេស ក្រោមអធិបតីភាព **លោកបណ្ឌិត ម៉ុក សារុំ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ។ កិច្ចប្រជុំនេះ បានពិភាក្សាអំពី ការធ្វើអត្រាកំណែ និងវាយតម្លៃដាក់ពិន្ទុ ដែលទទួលបានលទ្ធផលដូចខាងក្រោម ៖

**ក**- ពិភាក្សាលើគម្រោងអត្រាកំណែ និងកំណត់ពិន្ទុ មាន  សេចក្តីផ្តើម  តម្លៃផ្នែកអត្តរូប ឬតំណែងអ្នកនិពន្ធ តម្លៃផ្នែកអត្ថន័យ ឬ ខ្លឹមសារ  ( តម្លៃផ្នែកវប្បធម៌ , តម្លៃផ្នែកសង្គម ) តម្លៃផ្នែកអក្ខរស ឬ គុណតម្លៃ និងសន្និដ្ឋាន។

**ខ**- ការកែកិច្ចការបេក្ខជន និងវិនិច្ឆ័យ ដាក់ពិន្ទុកិច្ចការបេក្ខជន ២១ នាក់

**គ**- ការប្រជុំរបស់គណៈកម្មការ ដើម្បីវិនិច្ឆ័យ រៀបចំណាត់ថ្នាក់បេក្ខជន ជ័យលាភី ពីលេខ១ លេខ២ និងលេខ៣។



## IV -ការប្រារព្ធពិធីទិវាជាតិអំណាន១១ មីនា ២០១៨ លើកទី៣

សកម្មភាពប្រារព្ធទិវាជាតិអំណាន១១ មីនា ២០១៨ លើកទី៣ ត្រូវបានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ មានសកម្មភាព ខ្លឹមសារ និងលទ្ធផលដូចខាងក្រោម ៖

**ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨**

### ១-ការប្រារព្ធពិធីប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ

*ក-សមាសភាពគណៈអធិបតី និងអ្នកចូលរួម*




១.ឯកឧត្តម បណ្ឌិត **ណាត ប៊ុនរឿន** រដ្ឋមន្ត្រីស្តីទីក្រសួងអយក.
២.លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋ.ក្រសួងអយក.
៣.លោកជំទាវ **ច័ន្ទ ធី** រដ្ឋ.ក្រសួងវប្បធម៌និងសិល្បៈ
៤. លោកជំទាវ **ទន់ សារ៉ឹម** អនុ.ក្រសួងអយក.
៥. ឯកឧត្តម **យ៉ាង មូរិន** ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
៦. លោក **ឃឹម សារិន** អនុប្រ.នា អកស.
៧. លោក **ឃិន ធី** អនុប្រ.នា អកស.
៨. លោក **ង៉ា ឧុទ្ធី** អនុប្រ.នា អកស.
៩. លោក **ម៉ែន សុន** សាស្ត្រាចារ្យស.វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
១០. លោក លោកស្រី សមាជិកគណៈកម្មការរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៨
១១. លោក លោកស្រី ប្រតិភូរាជធានី ខេត្ត និងមាតាបិតា បេក្ខជនទាំងអស់
១៣.បេក្ខជន បេក្ខនារី ប្រកួតប្រជែង អាន ស្មូតកំណាព្យ និងតែងនិពន្ធ

សរុបអ្នកចូលរួមមាន ៥៣៥ នាក់ ។

*ខ-របាយការណ៍វឌ្ឍនភាពការងារប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ទិវាជាតិអំណាន ១១ មីនា ២០១៨ ដោយលោកជំទាវ **ទន់ សារ៉ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា*



លោកជំទាវបានបង្ហាញថា ក្រសួងអប់រំ យុវជន និងកីឡា បាន សហការជាមួយក្រសួងពាក់ព័ន្ធ បានរៀបចំអនុវត្តអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីពី ទិវាជាតិអំណាន ជារៀងរាល់ឆ្នាំ។ ការរៀបចំទិវាជាតិអំណានឆ្នាំ២០១៨នេះ ក្រសួងបានរៀបចំគណៈកម្មការរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៨ ដើម្បីឱ្យការរៀបចំកាន់តែមានភាពប្រសើរឡើង ជាពិសេសទំហំនៃការរៀបចំនេះកាន់តែមានទិដ្ឋភាពធំជាង២ឆ្នាំកន្លងមក។ ទន្ទឹមនេះ ក្រសួងបានរៀបចំសេចក្តីណែនាំ ជូនដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយជូនដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក គ្រឹះស្ថានសិក្សា សាធារណៈ និងឯកជន ឱ្យរៀបចំការប្រកួតប្រជែងការអាន ស្មូតកំណាព្យ និងការតែងនិពន្ធចាប់ពីដើមខែមករា រហូតដល់ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៨។ ខ្លឹមសារសំខាន់នៃសេចក្តីណែនាំនោះ បានបែងចែកជាបីដំណាក់កាល ៖

ដំណាក់កាលទី១ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សហការជាមួយអាជ្ញាធរមូលដ្ឋាន រៀបចំកម្មវិធីប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ដោយជ្រើសរើសយកចំណាត់ថ្នាក់លេខ១ ក្នុងក្របខណ្ឌក្រុង ស្រុក។

ដំណាក់កាលទី២ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក សហការជាមួយអាជ្ញាធរមូលដ្ឋាន ដៃគូរអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ រៀបចំការប្រកួតប្រជែងជ្រើសរើសបេក្ខជនជ័យលាភីលេខ១ ទាំងបីវិញ្ញាសា ដើម្បីចូលរួមប្រកួតប្រជែងជ័យលាភីនៅថ្នាក់ រាជធានី ខេត្ត ។

ដំណាក់កាលទី៣ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត សហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ រៀបចំប្រកួតប្រជែងជ្រើសរើសជ័យលាភីចំណាត់ថ្នាក់លេខ១ មកប្រកួតប្រជែងជ័យលាភីថ្នាក់ជាតិ។

ជារួម បេក្ខជនជ័យលាភីថ្នាក់រាជធានី ខេត្ត ដែលបានមកចូលរួមប្រកួតប្រជែងកម្រិតថ្នាក់ជាតិ មាន៖

១- បេក្ខជនប្រកួតប្រជែងអាន សម្រាប់សិស្សថ្នាក់ទី៦ មាន២៥ នាក់ ក្នុងនោះស្រីមាន១៨នាក់

២- បេក្ខជនប្រកួតប្រជែងសូត្រកំណាព្យ សម្រាប់សិស្សពីថ្នាក់ទី៧ដល់ទី៩ មាន២៥ នាក់ ក្នុងនោះស្រីមាន១៩នាក់

៣-បេក្ខជនប្រកួតប្រជែងតែងនិពន្ធ សម្រាប់សិស្សពីថ្នាក់ទី១០ ដល់ថ្ងៃទី១២ មាន២៣ នាក់ ក្នុងនោះស្រីមាន ១៨ នាក់។

បញ្ជាក់ ៖ ខេត្តមណ្ឌលគិរី និងក្រចេះ ជ្រើសរើសមិនបានបេក្ខជនជ័យលាភីសម្រាប់ការប្រកួតប្រជែងវិញ្ញាសាតែងនិពន្ធ សម្រាប់ថ្នាក់ជាតិបានទេ ។

*គ- ប្រសាសន៍សំណេះសំណាល និងអនុសាសន៍ របស់ឯកឧត្តម បណ្ឌិត **ណាត ម៉ុនរឿន** រដ្ឋមន្ត្រីស្ដីទី និងជារដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា*



ឯកឧត្តមរដ្ឋមន្ត្រីស្ដីទី បានថ្លែងអំណរគុណ ដល់ថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន និងក្រុមការងារដែលបានសហការរៀបចំទិវាជាតិអំណាន១១ មីនា ២០១៨ ជាលើកទី៣នេះឡើង និងបានមានប្រសាសន៍ពាក់ព័ន្ធនឹងប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " សម្រាប់ទិវាជាតិអំណាននេះថា ៖

១- រាជរដ្ឋាភិបាល បានសម្រេចជ្រើសរើសយកថ្ងៃទី១១ ខែមីនា ដែលជាថ្ងៃកំណើតរបស់សម្ដេច ព្រះសង្ឃរាជ **ជួន ណាត** ប្រារព្ធទិវាជាតិអំណាននេះឡើងរៀងរាល់ឆ្នាំ ដើម្បីរំឭកគុណដល់វីរភាព របស់ព្រះអង្គដែលបានខិតខំតស៊ូពុះពារការពារមរតកវប្បធម៌ អក្សរសាស្ត្រខ្មែរ ពីអាណានិគមនិយមបារាំង និងគោលបំណងបណ្ដុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួម ចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ និងការបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយវិជ្ជា សម្បទា បំណិនសម្បទា និងចរិយាសម្បទា សម្រាប់ការរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើនដូចអារ្យប្រទេសក្នុងសកលលោក។

២- អំណានដើម្បីអភិរក្ស និងអភិវឌ្ឍមានន័យថា ដោយសារអំណានបានធ្វើឱ្យយើងនឹកឃើញឡើងវិញជានិច្ច មិនអាចបំភ្លេចបានពីរបប ៣ ឆ្នាំ៨ ខែ និង២០ ថ្ងៃ ដែលបានធ្វើឱ្យរស់ឡើងវិញជានិច្ចនៅក្នុងទឹកចិត្តរបស់អ្នកអានពីរបបដ៏ព្រៃផ្សៃនេះ។ តាមរយៈស្ដង់ពិព័រណ៌សៀវភៅ គឺសៀវភៅទាំងឡាយត្រូវបានប្រមូល និងការបោះពុម្ពឡើងវិញ និងអភិរក្សពីអ្វីដែលមាននៅក្នុងខ្លឹមសារសៀវភៅនោះ។ ដូចនេះ ការបោះពុម្ពឡើងវិញ សូមរក្សាអត្តសញ្ញាណសៀវភៅដើមរបស់គេទាំងអស់។

៣-កម្មវិធីប្រកួតប្រជែងអាន សូត្រកំណាព្យ និងតែងនិពន្ធដែលរៀបចំឡើងដើម្បីដណ្ដើមយកជ័យលាភីថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់សម្ដេចតេជោហ៊ុន សែន** " គឺជាកត្តាដ៏សំខាន់ក្នុងការ

ជំរុញនិងដាស់ស្មារតីសិស្ស និស្សិត ប្រជាពលរដ្ឋ ឱ្យយកចិត្តទុកដាក់បង្កើតចំណង់ចំណូលចិត្តអាននិងបណ្តុះទម្លាប់អានពេញមួយជីវិត។

៤- បន្ទាប់ពីបានប្រារព្ធពិធីទិវាជាតិអំណាន២លើករួចមកហើយ ឯកសារដែលបានកប់បាត់យូរមកហើយ បានរស់ឡើងវិញ និងបានប្រមូលបោះពុម្ព និងអភិរក្ស។ ការរស់ឡើងវិញរបស់ឯកសារនេះយើងបានផ្សព្វផ្សាយ មិនត្រឹមតែកម្រិតជាតិប៉ុណ្ណោះទេ យើងបានផ្សព្វផ្សាយដល់កម្រិតអន្តរជាតិទៀតផង។

៥- កាលពីសម័យដើម យើងក៏មានការប្រឡងប្រណាំង ពានរង្វាន់ក្រមង៉ុយ និងឥន្ទ្រទេវី ដើម្បីអំណាននេះដែរ និងដោយខ្សែកកម្មវិធីប្រកួតប្រជែងនេះ យើងនឹងពង្រីកដល់កម្រិតឧត្តមសិក្សាដើម្បីឱ្យមានការចូលរួមកាន់ច្រើន។

៦-ការប្រារព្ធទិវាជាតិអំណាន១១ មីនា ២០១៨ លើកទី៣នេះ គណៈកម្មការ បានរៀបចំស្តង់តាំងពិព័រណ៍សៀវភៅមានលក្ខណៈពិសេសជាងកាលលើកទី១ និងទី២ ដែលពិសេសមាន ស្តង់ស្នាដៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** ដែលស្តង់នេះបានបង្ហាញពីលទ្ធផលស្នាដៃ និងជីវប្រវត្តិរបស់លោក និងស្តង់ឯកឧត្តម **បណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្ហាញពីស្នាដៃរបស់ឯកឧត្តមដោយមានសរសេរជាភាសាខ្មែរ បារាំង និងអង់គ្លេស។

៧-ជាក់ស្តែង ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ យើងនឹងរំលឹកឡើងវិញទាំងអស់គ្នា ដោយការចូលរួមច្រៀងចំរៀងបទពង្សាវតាខ្មែរ ដើម្បីដាស់សតិប្រជាជនខ្មែរថា ខ្មែរយើងមានវប្បធម៌ អរិយធម៌ ដ៏យូរលង់ណាស់មកហើយ ដូចនេះយើងត្រូវរួមគ្នាថែរក្សាឱ្យបានគង់វង្ស។

ចុងបញ្ចប់ **ឯកឧត្តម បណ្ឌិត** រដ្ឋមន្ត្រីស្តីទី បានសំណូមពរះ

- សូមគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រកួតប្រជែង ធ្វើការវាយតម្លៃដាក់ពិន្ទុដល់បេក្ខជនប្រកបដោយយុត្តិធម៌ ដើម្បីឱ្យបេក្ខជនឈ្នះដោយអស់ចិត្តប្រកបដោយកិត្តិយស។
- សូមឱ្យមានការចូលរួមពីសិស្សវិទ្យាល័យជិតៗ ទាំងនៅការប្រកួតប្រជែងកម្រិតរាជធានីខេត្ត និងថ្នាក់ជាតិ ដើម្បីពួកគេបានចូលរួមស្តាប់ស្វែងយល់ និងជួយផ្សព្វផ្សាយ។

## ២-ការសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅ

កម្មវិធីសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិត ណាត ម៉ុនរឿន** រដ្ឋមន្ត្រីស្តីទី និងជារដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកចូលក្នុងពិធីបើកការប្រារព្ធទិវាជាតិអំណាន១១ មីនា ២០១៨ លើកទី៣។



សកម្មភាពគណៈអធិបតីក្នុងពិធីសម្ពោធស្តង់ពិព័រណ៍

ស្តង់តាំងពិព័រណ៍សៀវភៅសរុបមាន២៧ស្តង់ ដែលមានរាយឈ្មោះស្តង់ ដូចក្នុងតារាងខាងក្រោម ៖

| ល.រ | ឈ្មោះស្តង់ | ចំនួន | ល.រ | ឈ្មោះស្តង់ | ចំនួន |
|---|---|---|---|---|---|
| 1 | សម្តេចព្រះសង្ឃរាជ **ជួន ណាត** | 1 | 2 | ក្រសួងអប់រំ យុវជន និងកីឡា | 1 |
| 3 | ឯកឧត្តម **បណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រី | 1 | 4 | កុមារ | 2 |
| 5 | Aide et Action | 1 | 6 | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | 2 |
| 7 | ស៊ីប៉ា | 1 | 8 | SVA | 1 |
| 9 | Room to Read | 1 | 10 | បណ្ណាល័យបញ្ញាវន្ត | 1 |
| 11 | ដាំដើមជីវិត | 3 | 12 | You car book | 1 |
| 13 | ធនធានសិក្សា | 1 | 14 | Father book | 1 |
| 15 | សង្គប្បអនុវត្ត | 1 | 16 | បណ្ណាគារ ប៉ៃណៃត | 1 |
| 17 | មូលនិធិ អាស៊ី | 1 | 18 | សេដ្ឋគុណ | 1 |
| 19 | យូខេនវីន | 2 | 20 | ម៉ាញ ប៊ុក្ស Mind-book | 2 |
| 21 | IYF World Camp in Cambodia | 1 | | | |
| សរុបរួម **២៧** ស្តង់ | | | | | |







សកម្មភាពគណៈអធិបតី និងអ្នកចូលរួមក្នុងពិធីសម្ពោធស្តង់ពិព័រណ៍

## ៣-កម្មវិធីប្រកួតប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ

ដំណើរការនៃកម្មវិធីប្រកួតប្រជែងការអាន ស្មូតកំណាព្យ និងតែងនិពន្ធ សម្រាប់ជ័យលាភី លេខ១ លេខ២ និងលេខ៣ " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ទាំងគណៈកម្មការវាយតម្លៃដាក់ពិន្ទុតាមវិញ្ញាសា និងបេក្ខជនប្រកួតប្រជែងទាំងអស់ ត្រូវបានរៀបចំ និងបែងចែកជាបីក្រុម តាមវិញ្ញាសានីមួយៗ និងមានសកម្មភាពដូចខាងក្រោម ៖

៣-១ *ក្រុមប្រកួតប្រជែងការអានអត្ថបទ*

**ក**-សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រកួតប្រជែងអាន

- លោកជំទាវ **ច័ន្ទ ធី** រដ្ឋលេខាធិការក្រសួងព័ត៌មាន
- លោក **ឃឹម សារិន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- លោក **យ៉ង់ កំសាន** អនុប្រ.ការិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- លោកស្រី **ម៉ៅ តាន់ណារី** អនុប្រ.ការិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**ខ**-បេក្ខជនប្រកួតប្រជែងការអានអត្ថបទ

បេក្ខជនប្រកួតប្រជែងអានមានចំនួន ២៥ នាក់ ក្នុងនោះស្រីមាន ១៨ នាក់ ជាសិស្សកំពុងរៀននៅថ្នាក់ទី៦ នៃសាលាបឋមសិក្សាក្នុងរាជធានី ខេត្តទាំង២៥។

**គ**-លក្ខណៈវិនិច្ឆ័យវាយតម្លៃដាក់ពិន្ទុ

លក្ខណៈវិនិច្ឆ័យ សម្រាប់ការវាយតម្លៃដាក់ពិន្ទុ លើការប្រកួតប្រជែងអានមាន ៖

- អានអត្ថបទបានលឿន គោរពឃ្លា ល្បះ បានត្រឹមត្រូវ ២ ពិន្ទុ
- សំឡេង/សំនៀងច្បាស់ៗ ត្រឹមត្រូវតាមសូររបស់ពាក្យ ៣ ពិន្ទុ
- មិនខុសពាក្យ មិនរំលងពាក្យ ៤ ពិន្ទុ
- ឥរិយាបថ សមរម្យ ១ ពិន្ទុ

**ឃ**-ដំណើការសកម្មភាព

បេក្ខជនម្នាក់ៗ ត្រូវបានឡើងអានអត្ថបទ តាមអត្ថបទរបស់ខ្លួនដែលបានជ្រើសរើសរៀងៗខ្លួន និងត្រូវបានពិនិត្យវាយតម្លៃដាក់ពិន្ទុ ដោយគណៈកម្មការវាយតម្លៃដាក់ពិន្ទុនៃវិញ្ញាសានេះ។

៣-២ *ក្រុមប្រកួតប្រជែងការស្មូតកំណាព្យ*

**ក**-សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រកួតប្រជែង ស្មូតកំណាព្យ



- ឯកឧត្តម **ជ័យ ចាប** ទីប្រឹក្សារាជរដ្ឋាភិបាល
- ឯកឧត្តម **យ៉ាន់ បូរិន្ទ** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លោក **ខិន សុតារា** អនុប្រ.ការិ.នាយកដ្ឋានអភិវឌ្ឍ
- លោក **យូ លក្ខិណា** អនុប្រ.ការិ.នាយកដ្ឋានអភិវឌ្ឍ

**ខ**-បេក្ខជនប្រកួតប្រជែងការ ស្មូតកំណាព្យ

បេក្ខជនប្រកួតប្រជែងស្មូតកំណាព្យ មានចំនួន ២៥ នាក់ ក្នុងនោះស្រីមាន ១៩នាក់ ជាសិស្សកំពុងរៀននៅថ្នាក់ទី៧ ដល់ទី៩ នៃវិទ្យាល័យនិងអនុវិទ្យាល័យ ក្នុងរាជធានី ខេត្តទាំង២៥។

**គ**-លក្ខណៈវិនិច្ឆ័យវាយតម្លៃដាក់ពិន្ទុ

លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃដាក់ពិន្ទុ លើការប្រកួតប្រជែងស្មូតកំណាព្យមាន ៖

- ទឹកដមពិរោះក្រអៅក្រអួន ស្តាប់ពិរោះ ៥ ពិន្ទុ
- ស្មូតត្រូវតាមបទ ( ឧ.បទពាក្យ ៧ ចំពាក្យ៧ ) ៣ ពិន្ទុ
- សំឡេងស្រែកមិនភ្លាត់ ១ ពិន្ទុ
- ទឹកមុខ ប្រែប្រួលតាមខ្លឹមសារ ១ ពិន្ទុ

**ឃ**-ដំណើការសកម្មភាព



បេក្ខជនម្នាក់ៗ ត្រូវបានឡើងស្មូតកំណាព្យ តាមអត្ថបទកំណាព្យបទ សូត្របែបដែលបេក្ខជនម្នាក់ៗបានជ្រើសរើសរៀងៗខ្លួន និងត្រូវបានពិនិត្យវាយតម្លៃដាក់ពិន្ទុ ដោយគណៈកម្មការវាយតម្លៃដាក់ពិន្ទុនៃវិញ្ញាសានេះ។

៣-៣ *ក្រុមប្រកួតប្រជែងការតែងនិពន្ធ*

**ក**-សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រកួតប្រជែងតែងនិពន្ធ

- លោកជំទាវ **ទន់ សារអ៊ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- លោក **ឃិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- លោក **ម៉ែន សុន** សាស្ត្រាចារ្យផ្នែកនិពន្ធកំណាព្យ
- លោក **ព្រៃ សំបូរ** អនុប្រ.ការិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**ខ**-បេក្ខជនប្រកួតប្រជែងការ តែងនិពន្ធ

បេក្ខជនប្រកួតប្រជែងតែងនិពន្ធមានចំនួន ២៣ នាក់ ក្នុងនោះស្រីមាន ១១ នាក់ ជាសិស្សកំពុងរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ នៃវិទ្យាល័យ ក្នុងរាជធានី ខេត្តចំនួន២៣។ ដោយឡែក ខេត្តមណ្ឌលគិរី និងក្រចេះ ធ្វើការជ្រើសរើសមិនបានបេក្ខជនជ័យលាភី សម្រាប់ការតែងនិពន្ធកំណាព្យទេ។

**គ**-លក្ខណៈវិនិច្ឆ័យវាយតម្លៃដាក់ពិន្ទុ

លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃដាក់ពិន្ទុ លើការប្រកួតប្រជែងតែងនិពន្ធកំណាព្យមាន ៖

- អត្ថរូប រចនាបថ ( វង្វាស់កាព្យ ចំណាប់ចួន ភាសាកាព្យ ) ៣ ពិន្ទុ
- អត្ថន័យ ( ត្រឹមត្រូវតាមប្រធានបទ) ៣ ពិន្ទុ
- អត្ថរស ( តម្លៃអប់រំ តម្លៃគុណធម៌ និងតម្លៃសីលធម៌ ) ៣ ពិន្ទុ
- អក្ខរាវិរុទ្ធ ១ ពិន្ទុ

ឃ-ដំណើរការសកម្មភាព

បេក្ខជនម្នាក់ៗ ត្រូវបានឡើងអានអត្ថបទកំណាព្យ ដែលបេក្ខជនម្នាក់ៗបានតែងនិពន្ធ ដោយមានការពិនិត្យវាយតម្លៃដាក់ពិន្ទុ ពីគណៈកម្មការវាយតម្លៃដាក់ពិន្ទុនៃវិញ្ញាសានេះ។

**ថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨**
**កម្មវិធីកំណត់ចំណាត់ថ្នាក់ជ័យលាភី និងការណែនាំបច្ចេកទេស**

**១**-*សមាសភាពគណៈអធិបតី និងអ្នកចូលរួម*

១. លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
២. លោកជំទាវ **ច័ន្ទ ធី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
៣. លោកជំទាវ **ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
៤. ឯកឧត្តម **យ៉ាង ម៉ូរិន** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
៥. លោក **ឃឹម សារិន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៦. លោក **យិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៧. លោក **ង៉ា ឧុត្តី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
៨. លោក **ម៉ែន សុន** សាស្ត្រាចារ្យសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩. លោក លោកស្រី សមាជិកគណៈកម្មការវាយតម្លៃដាក់ពិន្ទុ
១០.លោក លោកស្រី ប្រតិភូរាជធានី ខេត្តទាំង២៥
១២.មាតាបិតា បេក្ខជនប្រកួតប្រជែង អាន សូត្រកំណាព្យ និងតែងនិពន្ធ
១៣.បេក្ខជន បេក្ខនារី ប្រកួតប្រជែង អាន សូត្រកំណាព្យ និងតែងនិពន្ធ

សរុបអ្នកចូលរួមទាំងអស់ ១៥០ នាក់។

**២**-*ការពិនិត្យ និងវាយតម្លៃបេក្ខជនជ័យលាភី*

បេក្ខជនជ័យលាភីទាំង៣ វិញ្ញាសា អាន សូត្រកំណាព្យ និងតែងនិពន្ធ ត្រូវបានគណៈកម្មការឱ្យអាន និងសូត្រឡើងវិញ លើកលែងតែវិញ្ញាសាតែងនិពន្ធ។

**៣**-*ការប្រកាសបេក្ខជនជ័យលាភី*

បេក្ខជនជ័យលាភីលេខ១ លេខ២ លេខ៣ ទាំង៣ វិញ្ញាសា មាន ៖

**ក-ជ័យលាភី វិញ្ញាសា អានអត្ថបទ**




| លរ | ចំ.ថ្នាក់ | ថ្ងៃខែឆ្នាំកំណើត | ថ្នាក់ទី | មកពីសាលា | ចំណាងជើង |
|---|---|---|---|---|---|
| ១ | **១** | ០១-០២- ២០០៨ | ៦ | បឋម.សម្រស់កុមារ | ទេសភាពវាលស្រែ |
| ២ | **២** | ០៣-១១- ២០០៦ | ៦ | បឋម.សុខអានមង្គលមានលក្ខណ៍ | ទេសភាពវាលស្រែ |
| ៣ | **៣** | ១៦-០៨- ២០០៧ | ៦ | បឋម.ហាស តំបែរ | ទេសភាពវាលស្រែ |

ខ-ជ័យលាភី វិញ្ញាសា សូត្រកំណាព្យ




| លរ | បេក្ខជន | ថ្ងៃខែឆ្នាំកំណើត | ថ្នាក់ទី | មកពីសាលា | សូត្រ | កំណាព្យបទ | សូត្របែប |
|---|---|---|---|---|---|---|---|
| ១ | **១** | ០៩-០៣- ២០០៣ | ៩ | អនុ.បសេដ្ឋ | ចិត្តអើយចិត្តឯង | ពាក្យ ៧ | កុមារបាពិ |
| ២ | **២** | ០២-១០- ២០០១ | ៩ | អនុ.ហាស ឈូកជីព្រះ | គួរតែដឹង | ពាក្យ ៧ | ទំនួញ |
| ៣ | **៣** | ២៧-១០- ២០០ | ៧ | វិ.បាក់ទូក | តម្លៃនៃវប្បធម៌ | ពាក្យ ៧ | ទំនួញ |

គ-ជ័យលាភី វិញ្ញាសា តែងនិពន្ធកំណាព្យ




| លរ | បេក្ខជន | ថ្ងៃខែឆ្នាំកំណើត | ថ្នាក់ទី | មកពីសាលា | ប្រធានបទ | បទ |
|---|---|---|---|---|---|---|
| ១ | **១** | ១៨-០៨- ២០០០ | ១២ | វិ.សម្ដេចឪ | កំណប់វិជ្ជាជាសួនអំណាន | កាកគតិ |
| ២ | **២** | ១៧-០៣- ២០០០ | ១១ | វិ.បន.ហាស ចរិយាវង្ស | អំណានជាទ្រព្យដ៏ប្រសើរ | ពាក្យ ៧ |
| ៣ | **៣** | ០៥-០៤- ២០០០ | ១២ | វិ.ពញាក្រែក | អំណានជាទ្រព្យដ៏ប្រសើរ | ពាក្យ ៧ |

៤-*ការហ្វឹកហាត់កាយវិការបេក្ខជនជ័យលាភី*

ការហ្វឹកហាត់ត្រូវបានដឹកនាំដោយលោកជំទាវថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និង គណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រកួតប្រជែងអាន សូត្រកំណាព្យ និងតែងនិពន្ធ។ បេក្ខជនដែលបានទទួលការហ្វឹកហាត់ ជាបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ នៃវិញ្ញាសាទាំង៣ " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងការបកស្រាយប្រធានបទ " **តម្លៃសកលនៃស្នាដៃអក្សរសិល្ប៍ រឿងទុំទាវ** " ។ សកម្មភាពហ្វឹកហាត់មាន ៖

- ✓ ការហាត់ច្រៀងចម្រៀងបទពង្សាវតាខ្មែរ
- ✓ ការអានអត្ថបទ និងសូត្រកំណាព្យ សារឡើងវិញ
- ✓ ការហ្វឹកហាត់ឡើងទទួលពានជ័យលាភី
- ✓ ការណែនាំពីការរៀបចំស្លៀកពាក់ក្នុងថ្ងៃប្រារព្ធពិធី។

 

សកម្មភាពហ្វឹកហាត់ច្រៀងចម្រៀងបទពង្សាវតាខ្មែរ

**ថ្ងៃអាទិត្យ ១០រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨**
**កម្មវិធីពេលព្រឹក**

**១-សមាសភាពគណៈអធិបតី និងអ្នកចូលរួម**



១-លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

២-ឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

៣-ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន

៤-លោកជំទាវ **នាង ច័ន្ទថាណា** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា

៥-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៦-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ លោក លោកស្រី មកពីក្រសួងធម្មការ និងសាសនា វប្បធម៌និងវិចិត្រសិល្បៈ ព័ត៌មាន បរិស្ថាន អាជ្ញាធរសវនកម្មជាតិ រាជបណ្ឌិត្យសភាកម្ពុជា ក្រុមប្រឹក្សាជាតិភាសាខ្មែរ ធនាគារជាតិនៃកម្ពុជា បណ្ណាល័យជាតិ សមាគមបណ្ណារក្ស គណៈអភិបាលរាជធានីភ្នំពេញ។

៧- ប្រតិភូមន្ទីរអប់រំ យុវជន និងកីឡា២៥ រាជធានី ខេត្ត

៨- ដៃគូរអភិវឌ្ឍជាតិ អន្តរជាតិ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស

សរុបអ្នកចូលរួមក្នុងពិធីនេះ មាន ៣៩៦៦ នាក់។

**២-ការគោរពទង់ជាតិ និងច្រៀងចម្រៀងបទពង្សាវតារខ្មែរ**

បន្ទាប់ពីគោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជារួចមកអង្គពិធីទាំងមូលបានច្រៀងចម្រៀងបទពង្សាវតារខ្មែររួមគ្នាជាមួយសាស្ត្រាចារ្យមកពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីរំលឹកឡើងវិញនូវភាពថ្កើងថ្កាននៃពង្សាវតារខ្មែរ និងការដាស់សតិដល់អ្នកចូលរួម និងប្រជាជាតិទាំងមូលថាខ្មែរមានវប្បធម៌ អរិយធម៌ដ៏រុងរឿង ដែលយើងទាំងត្រូវតែថែរក្សាឱ្យបានទឹកដីដ៏រុងរឿងរបស់ខ្មែរ។

**៣-ការទស្សនាវីដេអូ ស្តីពី វឌ្ឍនភាពនៃអំណាននៅកម្ពុជា**

ឯកសារវីដេអូមានចំណងជើងថា " វឌ្ឍនភាពការងារអំណាននៅកម្ពុជា " ដែលបានសហការរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការចំនួន១០ ដែលបានកំពុងធ្វើការងាររួមគ្នាយ៉ាងសកម្មក្នុងការលើកកម្ពស់ការងារអំណាននៅកម្ពុជាពិសេសអំណានដំបូង។

**៤-របាយការណ៍របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**



ឯកឧត្តម **បណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់សេចក្តីរាយការណ៍ស្តីពី " *វឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណានពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៨* " ដែលមានខ្លឹមសារដូចខាងក្រោម៖

- អំណាន ជាធាតុដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលឆ្លើយតបបានទៅនឹងគោលដៅនៃការអប់រំជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍធនធានមនុស្ស។

- ការជ្រើសរើសយកថ្ងៃទី ១១ ខែមីនា ដែលជាថ្ងៃខែកំណើតរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** ដើម្បីប្រារព្ធទិវាជាតិអំណាននេះ ក្នុងគោលបំណងរំឭកដល់វីរភាពរបស់សម្តេចដែលបានខិតខំ តស៊ូពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរពីអាណានិគមនិយមបារាំង និងក្នុងគោលបំណងបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ។

- ការជំរុញ និងលើកកម្ពស់តួនាទីអំណានក្នុងវិស័យអប់រំ គឺជាកត្តាដ៏សំខាន់ និងចាំបាច់បំផុត ដើម្បីដាស់ស្មារតីដល់ប្រជាជនកម្ពុជាឱ្យចាប់ផ្តើមអាន ចូលចិត្តអាន និងបណ្តុះទម្លាប់អានពេញមួយជីវិត។

- ក្នុងការអនុវត្តអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រារព្ធទិវាជាតិអំណានពីលើករួចមកហើយ គឺលើកទី១ នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមប្រធានបទ "*បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន* " និងលើកទី២ នាថ្ងៃទី១១ ខែមីនា ២០១៧ ក្រោមប្រធានបទ ***"អានដើម្បីភាពសុខដុមនៃជីវិត"*** នៅវិទ្យាស្ថានជាតិអប់រំ។ ក្នុងការរៀបចំទិវាជាតិអំណានលើកទី២កន្លងមក ការរៀបចំប្រកួតប្រជែងអាន និងស្មូតកំណាព្យ គឺជាលើកដំបូង សម្រាប់ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ដែលមានការប្រកួតប្រជែងអានសម្រាប់សិស្សថ្នាក់

បេក្ខជនជ័យលាភីទាំងបីវិញ្ញាសាមាន ៖

**១-ជ័យលាភីអានអត្ថបទ**






- ជ័យលាភីលេខ១ សិស្សមកពីសាលាបឋមសិក្សាសម្រស់កុមារ ខេត្តបន្ទាយមានជ័យ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំនួន ៣,០០០,០០០ ៛ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៥០០,០០០ ៛។
- ជ័យលាភីលេខ២ សិស្សមកពីសាលាបឋមសិក្សាសុខអានមង្គលមានលក្ខណ៍ ខេត្តតាកែវ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់ រាជរដ្ឋាភិបាលចំនួន ២,០០០,០០០ ៛ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៤០០,០០០ ៛។
- ជ័យលាភីលេខ៣ សិស្សមកពីសាលាបឋមសិក្សាហ៊ុនសែនតំបែរ ខេត្តត្បូងឃ្មុំ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល១,០០០,០០០ ៛។

**២-ជ័យលាភីស្មូតកំណាព្យ**






- ជ័យលាភីលេខ១ សិស្សមកពីអនុវិទ្យាល័យបរសេដ្ឋ ខេត្តកំពង់ស្ពឺ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជ រដ្ឋាភិបាលចំនួន ៤,០០០,០០០ ៛ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៦០០,០០០ ៛។
- ជ័យលាភីលេខ២ សិស្សមកពីអនុវិទ្យាល័យ ហ៊ុនសែន ឈូកជីព្រះ ខេត្តកំពង់ធំ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ៣,០០០,០០០ ៛ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៥០០,០០០ ៛។

- ជ័យលាភីលេខ៣ សិស្សមកពីវិទ្យាល័យបាក់ទូក រាជធានីភ្នំពេញ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ចំនួន ២,០០០,០០០ រ ។

### ៣-ជ័យលាភីតែងនិពន្ធ






- ជ័យលាភីលេខ១ សិស្សមកពីវិទ្យាល័យសម្តេចឪ ខេត្តតាកែវ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំនួន ៦,០០០,០០០ រ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៨០០,០០០ រ ។
- ជ័យលាភីលេខ២ សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ចរិយាវង្ស ខេត្តកែប ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ៥,០០០,០០០ រ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៧០០,០០០ រ ។
- ជ័យលាភីលេខ៣ សិស្សមកពីវិទ្យាល័យពញាក្រែក ខេត្តត្បូងឃ្មុំ ទទួលបាន " **ពានរង្វាន់សម្តេចតេជោ ហ៊ុនសែន** " និងរង្វាន់ថវិកាលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំនួន ៤,០០០,០០០ រ និងពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចំនួន ៦០០,០០០ រ ។

### ៦- ការអានអត្ថបទដោយជ័យលាភីលេខ១

ប្អូនប្រុស រ៉ុន **សុវណ្ណរិទ្ធិ** ជាជ័យលាភីលេខ១ ផ្នែកអានអត្ថបទ បានឡើងអានរឿងនិទានមួយមាន ចំណងជើងថា " ក្តីប្រាថ្នារបស់កូនឫស្សី " ជូនអង្គពិធីទាំងមូល។



### ៧- ការសូត្រកំណាព្យដោយជ័យលាភីលេខ១

ប្អូនស្រី **ស៊ុយ សុភ័ក្រ្ត** ជាជ័យលាភីលេខ១ផ្នែកសូត្រកំណាព្យ បាន បានឡើងសូត្រកំណាព្យ មានចំណងជើងថា " កំណប់វិជ្ជាជាសួនអំណាន " ដែលជាស្នាដៃនិពន្ធរបស់ប្អូនប្រុស **សោ គីមស្រួយ** ជាជ័យលាភីលេខ១ ផ្នែកតែងកំណាព្យ តាមលំនាំបទកាកគតិ ជូនដល់អង្គពិធីទាំងមូល។



## ៨- ការប្រគល់ប្រកាសនីយបណ្ណ និងប្រាក់រង្វាន់លើកទឹកចិត្ត ក្នុងការប្រកួតប្រជែងបកស្រាយប្រធានបទ "តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍រឿងទុំទាវ"

ក្នុងចំណោមបេក្ខជន២១ រូប ដែលបានចូលរួមប្រកួតប្រជែងបកស្រាយប្រធានបទ "**តម្លៃសកលរបស់ស្នាដៃអក្សរសិល្ប៍ រឿង ទុំទាវ**" ដើម្បីទទួលបានរង្វាន់លើកទឹកចិត្តពី **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានបេក្ខជនចំនួន៣រូប ដែលត្រូវទទួលបានប្រកាសនីយប័ណ្ណនិងរង្វាន់លើកទឹកចិត្តនេះ ពី **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ។



បេក្ខជនជ័យលាភី មាន៖

១-ជ័យលាភីលេខ១ លោក **ណន ម៉ារ៉ាឌី** គ្រូបង្រៀន នៅវិទ្យាល័យទួលទំពូង រាជធានីភ្នំពេញ

២-ជ័យលាភីលេខ២ លោក **ពៅ វណ្ណៈ** គ្រូបង្រៀន នៅវិទ្យាល័យព្រះម្លូ ខេត្តពោធិ៍សាត់

៣-ជ័យលាភីលេខ៣ លោក **ព្រឹម ប្រាក់ស្មី** គ្រូបង្រៀន នៅវិទ្យាល័យមិត្តភាពកម្ពុជា ជប៉ុនកំពតក្រុង ខេត្តកំពត។

## ៩- ពិធីប្រគល់សៀវភៅអប់រំផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

ក្នុងខែមីនា ឆ្នាំ២០១៦ កន្លងមក ធនាគារជាតិនៃកម្ពុជាសហការជាមួយអង្គការGood Return បានចាប់ផ្តើមយុទ្ធនាការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលមានឈ្មោះថា "**តោះនិយាយពីលុយ**" មានគោលបំណងផ្តល់ការអប់រំផ្នែកហិរញ្ញវត្ថុ ដោយជំរុញ និងលើកទឹកចិត្តយុវជនឱ្យពិភាក្សាពីសារៈសំខាន់នៃការគ្រប់គ្រងប្រាក់នៅក្នុងគ្រួសារ និងស្វែងរកព័ត៌មានបន្ថែមសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវក្នុងការទទួលយកសេវាហិរញ្ញវត្ថុ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានផលិតសៀវភៅដែលមានចំណងជើងថា "**តោះនិយាយពីលុយ**" ជាប្រភេទសៀវភៅអានបន្ថែមសម្រាប់ជួយដល់សិស្សបឋមសិក្សាពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ លើបំណិនអាន។ ខ្លឹមសារសៀវភៅបានបរិយាយពីវិធីការខ្ចីលុយ សងលុយ និងមានលំហាត់បន្ថែមអនុវត្តដើម្បីបានសិក្សាស្វែងយល់បន្ថែមអំពីផ្នែកហិរញ្ញវត្ថុ ស្របនឹងពេលដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងរៀបចំកំណែទម្រង់កម្មវិធីសិក្សា ដោយខ្លឹមសារនេះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាចំណេះទូទៅពីថ្នាទី១ ដល់ទី១២ លើមុខវិជ្ជាសីលធម៌ពលរដ្ឋ និងគេហសេដ្ឋកិច្ចវិទ្យា ។

ពិធីប្រគល់សៀវភៅអប់រំផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដែលមានចំណងជើងថា "**តោះនិយាយអំពីលុយ**" ត្រូវបាន **លោកជំទាវ នាង ច័ន្ទថាណា** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជាផ្តល់ជូនជានិមិត្តរូប ជូនដល់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលជាការឆ្លុះបញ្ចាំងពីកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយធនាគារជាតិនៃកម្ពុជាក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ។

## ១០- ប្រសាសន៍សំណេះសំណាលរបស់លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច



ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ឧបនាយករដ្ឋមន្ត្រី** មានខ្លឹមសារដូចខាងក្រោម៖

- សម្តែងការអបអរសាទរ និងកោតសរសើរចំពោះក្រសួងអប់រំ យុវជន និងកីឡាដែលបានសហការ ជា មួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ខិតខំប្រឹងប្រែងជំរុញ និងលើកកម្ពស់ តួនាទីអំណានក្នុងវិស័យអប់រំ ព្រមទាំងពង្រីកវិសាលភាពបានទូលំទូលាយនៅទូទាំងប្រទេសក្នុងការប្រារព្ធទិវាជាតិអំណានរៀង រាល់ឆ្នាំប្រកបដោយភាពអធិកអធម ក្នុងបំណងជំរុញស្មារតីប្រជាពលរដ្ឋកម្ពុជា ឱ្យបង្កើនការចាប់អារម្មណ៍ចំពោះការអាន បង្កើតទម្លាប់អាន និងបង្កើនការតែងនិពន្ធ ដោយយកអស់កម្លាំងកាយ និងប្រាជ្ញា ។
- សំដែងការកោតសរសើរចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានខិតខំយកចិត្តទុកដាក់ និងទំនួលខុសត្រូវខ្ពស់ក្នុងកំណែទម្រង់របស់វិស័យអប់រំជាគន្លឹះចំនួន ៨ចំណុចសម្រាប់ឆ្នាំ២០១៣-២០១៥ និង១៥ចំណុចក្នុងឆ្នាំ២០១៦-២០១៨ ឱ្យកាន់តែប្រសើរឡើង និងទទួលបានជោគជ័យជាបន្តបន្ទាប់។ ជាពិសេស ការបង្កើតទិវាជាតិអំណានដែលជាកត្តាចាំបាច់បំផុត ដើម្បីលើកកម្ពស់វប្បធម៌អាន និងបណ្តុះទម្លាប់អានពេញមួយជីវិតដល់ សិស្ស និស្សិត និងប្រជាពលរដ្ឋកម្ពុជា។
- លោកជំទាវឧបនាយករដ្ឋមន្ត្រី បានសំដែងមោទនភាពក្រៃលែង ដោយរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជ្រើសរើសយកថ្ងៃទី១១ ខែ មីនា ដែលជាថ្ងៃខែកំណើតរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** ដើម្បីប្រារព្ធទិវាជាតិអំណាននេះ និងជាការគោរពដឹងគុណវីរភាពរបស់សម្តេចព្រះសង្ឃរាជ ដែលបានខិតខំតស៊ូពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរពីអាណានិគមនិយមបារាំង ។
- លោកជំទាវ បានបង្ហាញថា ការប្រារព្ធទិវាជាតិអំណានលើកទី៣នេះ ស្ថិតក្រោមប្រធានបទ "**អំណានជាកំណប់វិជ្ជាមហាសាល**" ជាមួយពាក្យស្លោកមួយចំនួនដូចខាងក្រោម៖
    - អំណានដើម្បីបណ្តុះទម្លាប់រៀនពេញមួយជីវិត
    - អំណានលើកកម្ពស់អត្តសញ្ញាណជាតិ
    - អំណានថ្ងៃនេះ សម្រាប់ថ្ងៃស្អែក
    - អំណានជាប្រភពនៃទ្រព្យមិនចេះរីងស្ងួត
    - អំណានជាវឌ្ឍនភាពនៃវិជ្ជា
    - អំណានជាគន្លឹះនៃចំណេះដឹង
    - អានច្រើនកើនចំណេះ
    - អំណានលើកតម្កើងវប្បធម៌ជាតិ
    - អំណានជាមូលដ្ឋានគ្រឹះនៃចំណេះវិជ្ជា
    - វប្បធម៌អាន ជាគ្រឿងអលង្ការរបស់មនុស្សទូទៅ

- លោកជំទាវឧបនាយករដ្ឋមន្ត្រី បានបង្ហាញពីមាគ៌ា សន្តិភាព និងការអភិវឌ្ឍថា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយបញ្ញាញាណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គ្រប់វិស័យទាំងអស់មានភាពរីកចម្រើន និងអភិវឌ្ឍជាបន្តបន្ទាប់ ជាពិសេសវិស័យអប់រំ ដែលទទួលបានលទ្ធផលគួរជាទីមោទនទាំងបរិមាណ និងគុណភាព។ ជោគជ័យទាំងនេះបានឆ្លុះបញ្ចាំងពីភាពរឹងមាំនៃសន្តិភាព សន្តិសុខសាធារណៈ និងស្ថិរភាពនយោបាយ។ ប៉ុន្តែការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យាបានទាមទារឱ្យយើងខិតខំបន្តកែលម្អ និងពង្រឹងគុណភាពអប់រំបន្ថែមទៀត សំដៅឈានទៅសម្រេចបានជោគជ័យយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ដូច្នេះ ការពិនិត្យមើលឡើងវិញ ការពង្រឹង និងការបណ្តុះបណ្តាលសមត្ថភាព គុណភាពនៃធនធានមនុស្សលើគ្រប់វិស័យគឺជាភាពចាំបាច់ដែលក្រសួងនីមួយៗ ត្រូវយកចិត្តទុកដាក់សំដៅធ្វើយ៉ាងណាធានានូវគុណភាព និងសមត្ថភាពរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់ ទាំងនិស្សិត សិស្សានុសិស្សគ្រប់កម្រិត និងពលរដ្ឋទូទៅឱ្យគេមានចំណេះដឹងទូលំទូលាយតាមរយៈការបណ្តុះទម្លាប់អានពេញមួយជីវិត ដើម្បីពង្រឹងសមត្ថភាពចំណេះដឹងទូទៅជំនាញឯកទេស និងភាសាបរទេស ជាមធ្យោបាយផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ឱ្យបានទូលំទូលាយទាំងក្នុងនិងក្រៅប្រទេស ជាការឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

- លោកជំទាវ បានផ្តល់អនុសាសន៍ថា ចំពោះមុខ ការអភិវឌ្ឍធនធានមនុស្សប្រកបទៅដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែកដើម្បីសាងសង្គមកម្ពុជាឱ្យរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើ ជាមូលដ្ឋានឱ្យកាន់តែល្អប្រសើរឡើង ក្រសួងអប់រំ យុវជន និងកីឡាត្រូវបន្តអនុវត្តដូចខាងក្រោម៖
  - **ទី១.** ស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាលដើម្បីពិនិត្យលទ្ធភាពដាក់បញ្ចូលទិវាជាតិអំណាន ១១ មីនា ទៅក្នុងប្រតិទិនបុណ្យជាតិសម្រាប់ឆ្នាំខាងមុខ
  - **ទី២.** រៀបចំសារាចរណែនាំដល់គ្រប់ស្ថាប័នជាតិ អន្តរជាតិ គ្រឹះស្ថានសាធារណៈ និងឯកជន ជំរុញឱ្យអនុវត្តទិវាជាតិអំណា ១១ មីនា ប្រកបដោយប្រសិទ្ធភាពខ្ពស់
  - **ទី៣.** សហការជាមួយស្ថាប័ននានា និងដៃគូអភិវឌ្ឍប្រារព្ធទិវាជាតិអំណាន នាឆ្នាំបន្តបន្ទាប់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស
  - **ទី៤.** ជំរុញនិងលើកកម្ពស់ការតែងនិពន្ធឱ្យកាន់តែផុលផុស ព្រមទាំងបង្កើតស្នាដៃបានច្រើនប្រភេទសម្រាប់អ្នកអានគ្រប់វ័យ និងផ្គត់ផ្គង់សៀវភៅសិក្សាឱ្យបានសម្បូរបែបទាំងនៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន ដើម្បីជាមូលដ្ឋាននៃការចាប់យកគំនិតល្អៗ និងចំណេះដឹងសំខាន់ៗដែលពួកគេត្រូវការ។

- លោកជំទាវ ឧបនាយករដ្ឋមន្ត្រីបានអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ និង សប្បុរសជនទាំងអស់ សូមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បន្តប្រពៃណីចែករំលែកជួយឧបត្ថម្ភគាំទ្រដល់ការប្រារព្ធទិវាជាតិអំណាន១១ មីនា ដោយបង្កើតឱ្យមានកម្មវិធីកាន់តែសម្បូរបែប ប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងមានភាពអធិកអធម ។

- ជាមួយនឹងការអបអរសាទរ នៃទិវាជាតិអំណាន ក៏ដូចជាអបអរសាទរចំពោះបេក្ខជនជ័យលាភី ផ្នែកអាន សូត្រកំណាព្យ តែងនិពន្ធ និងអបអរសាទរជាមួយនឹងក្រុមគ្រួសារដែលទទួលបានជ័យលាភី លោកជំទាវបានប្រគេនពរ និងជូនពរ ដល់អ្នកចូលរួមទាំងអស់ សូមប្រកបដោយពុទ្ធពរ និងពរទាំងប្រាំប្រការ អាយុវណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យស្មារតី១១ មីនា នេះ ស្ថិតនៅជាអមតៈដល់ប្រជាជនកម្ពុជា ដើម្បីរួមចំណែកអភិរក្សអក្សរសាស្ត្រជាតិ និងរក្សាមរតវប្បធម៌ អរិយធម៌ជាតិ ឱ្យស្ថិតនៅគង់វង្សយូរអង្វែង។

## ១១- បាឋកថាឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បាឋកថារបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ** បានផ្តោតលើប្រធានបទ ស្តីពី " ***ការវិវត្ត នៃអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ*** " ដែលមានខ្លឹមសារសំខាន់ដូចខាងក្រោម ៖

- ចលនាអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ និងទិដ្ឋភាពអក្សរសិល្ប៍សម័យអង្គរ
- ការធ្លាក់ចុះ និងការចាកចោលអង្គរ
- បុព្វហេតុនៃការចាកចោលអង្គរ
- អក្សរសិល្ប៍ពុទ្ធនិយម
- អក្សរសិល្ប៍ពុទ្ធនិយមពិត និងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ
- វប្បធម៌ខ្មែរនៅសតវត្សទី១៨ និងទី១៩
- អត្ថន័យអក្សរសិល្ប៍ខ្មែរ

ជារួម ខ្លឹមសារបានបង្ហាញថា វណ្ណកម្មគ្មានពីររបស់ខ្មែរ ប្រសិនបើគ្មានការតស៊ូរបស់កវីនិពន្ធ នោះតម្លៃអក្សរសិល្ប៍ខ្មែរ មិនមានស្ថេរភាពមកដល់សព្វថ្ងៃនេះទេ។ គោលដៅរបស់យើង គឺគាស់កំណាប់ មហាសាលដែលមាននៅក្នុងអក្សរសិល្ប៍ យកមកលើកបង្ហាញដល់សិស្ស និស្សិតបានសិក្សាស្រាវជ្រាវ ជាពិសេសគំនិតសំខាន់ គឺចង់បំផុសឱ្យមានការស្រឡាញ់ ចូលចិត្តកំណាព្យ ។

## ១២- ពិធីផ្សព្វផ្សាយសៀវភៅ series of lectures in Public International law ដែលជាស្នាដៃនិពន្ធដោយ ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ក-សារតា

ឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** ក្នុងនាមជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសភាចារ្យ បានបំពេញភារកិច្ចដោយមិនខ្លាចការនឿយហត់ក្នុងទិសដៅអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ពោលគឺចូលរួម និងជំរុញការថែទាំទំពាំងឱ្យបានរឹងមាំ ដើម្បីក្លាយជាឫស្សីដ៏ល្អ ។ ស្របពេលជាមួយគ្នានេះ ឯកឧត្តមបានជំរុញការសរសេរ និងការអាន ដូចដែលឯកឧត្តមបានមានប្រសាសន៍ជារឿយៗថា " ការអានគឺមូលដ្ឋានគ្រឹះនៃចំណេះដឹង " ហើយដើម្បីចំណេះដឹងអាចឋិតថេរយូរអង្វែងបានដាច់ខាតត្រូវតែសរសេរ។

យល់ឃើញបញ្ហានេះ បានជំរុញឯកឧត្តមបានចូលរួមយ៉ាងសកម្មក្នុងការសរសេរ និងនិពន្ធសៀវភៅបានជាច្រើន។ ដោយឡែក ថ្ងៃនេះជាថ្ងៃប្រកបដោយនក្ខត្តឫក្សដែល **ឯកឧត្តម បណ្ឌិតសភាចារ្យ** បានបោះពុម្ព និងផ្សព្វផ្សាយសៀវភៅជាស្នាដៃទី១៩ ដែលមានចំណងជើងថា series of lectures in Public International law។

### ខ-ពិធីផ្សព្វផ្សាយ

សៀវភៅជាស្នាដៃរបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ** ដែលមានចំណងជើងថា series of lectures in Public International law ត្រូវបានចែកជូនដល់សាកលវិទ្យាល័យមួយចំនួន សម្រាប់សាស្ត្រាចារ្យ និស្សិតសិក្សាស្រាវជ្រាវ ប្រើប្រាស់ ដោយតំណាងមកពីសាកលវិទ្យាល័យមួយចំនួនបានទទួលសៀវភៅនេះ ជានិមិត្តរូបពី **ឯកឧត្តម បណ្ឌិតសភាចារ្យ** ដើម្បីយកទៅប្រើប្រាស់ មានដូចជា ៖

១-ឯកឧត្តម **ហោ ប៉េង** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

២-ឯកឧត្តម **លុច ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៣-ឯកឧត្តម **អ៊ុំ រមនី** នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
៤-លោក **ប៉ាល់ ដែស** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ







### ១៣- ការទស្សនាស្តង់តាំងពិព័រណ៍សៀវភៅ

ស្តង់តាំងពិព័រណ៍សៀវភៅទាំងអស់មាន ២៧ស្តង់ ដែលក្នុងនោះមានស្តង់តាំងសៀវភៅជាស្នាដៃរបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ** ស្តង់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ស្តង់ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិ។ ដោយឡែកក៏មានស្តង់តាំងអបអរសាទរទិវាជាតិអំណាន ១១ មីនា ២០១៨ លើកទី៣ សម្រាប់អ្នកចូលរួម និងមហាជនបានទស្សនា និងថតរូបជាអនុស្សាវរីយ៍ ។

ស្តង់ពិព័រណ៍ទាំងអស់មានលក្ខណៈប្រហាក់ប្រហែលគ្នា គឺការតាំងបង្ហាញ និងលក់សៀវភៅអាន ដែលអ្នកទស្សនាអាចជាវយកទៅអាន និងប្រើប្រាស់តាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់ខ្លួន។ ដោយឡែកស្តង់របស់ក្រសួងអប់រំ មានតាំងបង្ហាញពីឯកសារជាសមិទ្ធិផលរបស់អង្គភាព ក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា អ្នកទស្សនាអាចខ្ចីយកទៅថតចម្លង និងអានបាន ដោយទំនាក់ទំនង និងធ្វើពាក្យស្នើសូមខ្ចីនៅបណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន បឹងត្របែក ក្នុងបរិវេណវិទ្យាល័យបឹងត្របែក។

ស្តង់ទាំងអស់ត្រូវបានចូលទស្សនា ជាវសៀវភៅ ថតរូប និងអាន ដោយឯកឧត្តម លោកជំទាវ សមាជិក នៃអង្គពិធីទិវាជាតិអំណានទាំងមូល សិស្ស និស្សិត និងមហាជនទូទៅ។



**កម្មវិធីពេលរសៀល**

*១-ការស្មូតកំណាព្យដោយជ័យលាភី លេខ២*

ស្មូតដោយបេក្ខជន **ជន់ វណ្ណលោន** ជ័យលាភីលេខ២ ផ្នែកស្មូតកំណាព្យ មកពីអនុវិទ្យាល័យ ហ៊ុន សែន ឈូកជីព្រះខេត្តកំពង់ធំ សូត្របទពាក្យ៧ មានចំណងជើងថា អំណានជាទ្រព្យដ៏ប្រសើរ។ អត្ថបទនេះនិពន្ធដោយកញ្ញា **ចែម ស្រីពេជ្រ** ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ មកពីវិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែន ចរិយាវង្ស ខេត្តកែប។

*២-កិច្ចពិភាក្សា អធិប្បាយអត្ថបទអក្សរសិល្ប៍ ប្រធានបទ " តម្លៃសកលនៃស្នាដៃអក្សរសិល្ប៍រឿងទុំទាវ "*

កិច្ចពិភាក្សានេះសម្របសម្រួលដោយ លោកស្រីបណ្ឌិត **ឃួន វិច្ឆិកា** អគ្គនាយករងនៃ





អគ្គនាយកដ្ឋានអប់រំ និងស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវ ជន និងកីឡា។ វាគ្មិនក្នុងឱកាសនេះមាន៖

១- លោក **ណាន ម៉ារាឌី** ជ័យលាភីលេខ១ ជាសាស្ត្រាចារ្យមកពីវិទ្យាល័យទួលទំពូង

២- លោក **ពៅ វណ្ណៈ** ជ្ជយលាភីលេខ២ ជាសាស្ត្រាចារ្យមកពីវិទ្យាល័យក្នុងខេត្តពោធិ៍សាត់

ខ្លឹមសារសំខាន់នៃតម្លៃសាកលរបស់រឿងទុំទាវ បានបង្ហាញពី ប្រពៃណី សាសនា ទំនៀមទំលាប់ ជំនឿ ផ្នត់គំនិត របបគ្រប់គ្រង ជាពិសេសការសរសេរជាភាសាបែបសាមញ្ញងាយអាន ងាយយល់ មានភាពទាក់ទាញសម្រាប់អាន រៀន និងអប់រំកូនខ្មែរ ហើយរឿងនេះក៏ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាតាំងពីទសវត្សទី៦០ រហូតដល់បច្ចុប្បន្ននេះ។

សំណួរពីមហាជន តើរឿងទុំទាវបានឆ្លើយតបទៅនឹងទីផ្សារការងារបច្ចុប្បន្នដែរ ឬទេ ?

ចម្លើយ មានការអប់រំសីលធម៌ដើម្បីរស់នៅក្នុងសង្គម ពិសេសផ្លាស់ប្តូរអត្តចរិតពីមិនល្អមកល្អ។

*៣-ស្មូតកំណាព្យជ័យលាភីលេខ៣*

ស្មូតដោយបេក្ខនារី **ជា ស្រីភា** ជ័យលាភីលេខ៣ ផ្នែកស្មូតកំណាព្យ មកពីវិទ្យាល័យ បាក់ទូក រាជធានីភ្នំពេញ សូត្របទពាក្យ៧ មានចំណងជើង " វិជ្ជាជាទ្រព្យដ៏ប្រសើរ " និងអត្ថបទនេះ និពន្ធដោយបេក្ខជន **យ៉ឺន ឈុនអ៊ុយ** ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ មកពីវិទ្យាល័យ ពញាក្រែក ខេត្តត្បូងឃ្មុំ។

*៤-កិច្ចពិភាក្សាលើប្រធានបទ " ការតែងនិពន្ធនៅប្រទេសកម្ពុជា "*

កិច្ចពិភាក្សានេះសម្របសម្រួលដោយ លោកបណ្ឌិត **រស់ សុខាចា** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ។ វាគ្មិនក្នុងឱកាសនេះមាន៖

១- លោកស្រី **ប៉ុល ពិសី** អនុប្រធានសមាគមអ្នកនិពន្ធខ្មែរ និងជាទីប្រឹក្សាសមាគមទ្រទ្រង់ការបោះពុម្ព និងអប់រំ

២- លោក **ម៉ែន សុន** សាស្ត្រាចារ្យផ្នែកនិពន្ធ មហាវិទ្យាល័យសិល្បៈ និងនាដសាស្ត្រនៃសាលាភូមិន្ទវិចិត្រសិល្បៈ

៣-កញ្ញា **គឹម ឌីណា** អ្នកនិពន្ធ និងជាពិធីការនីឯករាជ្យ

ប្រធានបទ ៖ តើយល់ដូចម្ដេចដែរចំពោះការតែងនិពន្ធនៅកម្ពុជា ?

- កំណាព្យជាអត្ថបទអក្សរសិល្ប៍ដើម្បីអន្ទងសញ្ចេតនារបស់អ្នកស្ដាប់ ដែលអ្នកនិពន្ធត្រូវមានដួងចិត្តជាកវី បើមិនដូចនោះការនិពន្ធនឹងមិនទទួលបានការគាំទ្រ និងអាន ពីអ្នកអានឡើយ។

- ការលំបាកក្នុងការតែងនិពន្ធ គឺការរកទស្សនៈដោយឡែក ឱ្យខុសពីអ្នកនិពន្ធជើងចាស់កន្លងមក និងអ្នកនិពន្ធមានឱកាសកាន់តែច្រើន ដោយសារមានការគាំទ្រពីអ្នកអាន។

- យើងជាអ្នកនិពន្ធត្រូវតាំងចិត្តថា កុំខ្វល់ខ្វាយខ្លាចការតិះទៀនពីអ្នកដទៃ នៅអ្វីដែលយើងបានសរសេរ ព្រោះថាការសរសេរនិពន្ធ តែងមានការតិះទៀនជាប្រចាំ តែសំខាន់ពេលនោះ ពេលគេតិះទៀនយើងមានន័យថា គេបានអានស្នាដៃរបស់យើង ។

សំណួររបស់ **រឿន សុខេង** និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឯកទេសអក្សរសាស្ត្រខ្មែរ

តើត្រូវមានដើមទុនអ្វីខ្លះ ដើម្បីក្លាយជាអ្នកនិពន្ធដ៏មានប្រសិទ្ធភាព ?

ចម្លើយ ត្រូវពូកែអាន ព្យាយាមមើលស្នាដៃរបស់អ្នកនិពន្ធចាស់ៗ សិក្សារឿងរ៉ាវគ្រប់បែបយ៉ាងរបស់ជីវិត និង ការហ៊ានសរសេរ។

## V. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

### ក-សេចក្ដីសន្និដ្ឋាន

ដំណើរការប្រារព្ធពិធីទិវាជាតិអំណាន ៨ មីនា ឆ្នាំ២០១៨ លើកទី៣ ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានប្រព្រឹត្តទៅយ៉ាងរលូន តាមកម្មវិធីដែលក្រុមការងាររៀបចំទិវាជាតិអំណានបានគ្រោងទុក។ជាលទ្ធផល អ្នកចូលរួមទាំងអស់មានចំណាប់អារម្មណ៍ និងសប្បាយរីករាយ ចំពោះការប្រារព្ធទិវាជាតិអំណាននេះ ដោយពួកគេបានបង្ហាញកាន់តែច្បាស់ថែមទៀត អំពីសារប្រយោជន៍នៃតម្លៃការអានតាមរយៈ បាឋកថារបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ការបង្ហាញពីបទពិសោធន៍នៃអាជីពការងាររបស់វាគ្មិនល្បីៗ និងជាពិសេសនោះស្តង់ពិព័រណ៍បង្ហាញសៀវភៅដែលជាស្នាដៃរបស់កវីនិពន្ធជើងចាស់ល្បីៗនិងស្នាដៃកូនខ្មែរដែលជាអ្នកនិពន្ធជំនាន់ថ្មី ។

ជារួម សារសំខាន់ជាស្មារតីទិវាជាតិអំណាន ១១ មីនា ឆ្នាំ២០១៨ លើកទី៣នេះ គឺ

" **ការលើកទឹកចិត្តឱ្យគ្នាទៅវិញទៅមក ដើម្បីចូលរួមចំណែកលើកតម្កើងវប្បធម៌អំណាន** "

### ខ-អនុសាសន៍

ដើម្បីឱ្យសមិទ្ធផលដែលទទួលបានពីការប្រារព្ធពិធីទិវាជាតិអំណាន១១ មីនា ឆ្នាំ២០១៨ លើកទី៣នេះ ត្រូវបានពង្រីកនិងអនុវត្ត និងឆ្លើយតបទៅនឹងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ក្នុងការកសាងសង្គមកម្ពុជាឱ្យរីកចម្រើនផ្អែកលើ ចំណេះដឹង និងចំណេះ

ធ្វើជាមូលដ្ឋាន និងការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណាន ១១មីនា ឆ្នាំ២០១៩ លើកទី៤ ដែលនឹងប្រព្រឹត្ត ទៅនៅខេត្តសៀមរាប ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុសាសន៍របស់ **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ,ថ្ងៃច័ន្ទ ៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១៨

បានឃើញ និងឯកភាព
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

អ្នកធ្វើរបាយការណ៍

**សាម សារុំ**